**JICA Cambodia Office - JICA カンボジア事務所**
August 29 at 5:03 PM ·

**[សិក្ខាសាលាស្តីអំពីការបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាកក្នុងប្រទេសកម្ពុជា /Workshop for Developing National Guideline of In-Service Training (INSET) for Nurses in Cambodia]**

**------------------------------**

**គម្រោងរបស់ JICA សម្រាប់ពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា (The Strings) បានរៀបចំសិក្ខាសាលាលើកទីមួយនៅខេត្តកំពត រយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ២៦ ខែសីហា ដើម្បីបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាកក្នុងប្រទេសកម្ពុជា។ គម្រោងនឹងបន្តរៀបចំសិក្ខាសាលាចំនួន៣លើក នៅក្នុងខែសីហា កញ្ញា និងតុលា ឆ្នាំ ២០២២នេះ។ សិក្ខាកាមដែលចូលរួមគឺអញ្ជើញមកពីក្រុមការងារបច្ចេកទេស និងគណៈកម្មការគ្រប់គ្រងរបស់គម្រោង រួមមានសមាជិកមកពីនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល មន្ទីរពេទ្យជាតិ (មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមន្ទីរពេទ្យកុមារជាតិ) គណៈគិលានុបដ្ឋាកកម្ពុជា និងសមាគមគិលានុបដ្ឋាកកម្ពុជា។ ក្នុងអំឡុងពេលសិក្ខាសាលា សមាជិករបស់ក្រុមការងារបច្ចេកទេសបានធ្វើការពិភាក្សាយ៉ាងសកម្មទៅលើសេចក្តីសង្ខេបនៃគោលការណ៍ណែនាំថ្នាក់ជាតិនេះ។**

**យើងខ្ញុំរំពឹងថាសមត្ថភាពរបស់គិលានុបដ្ឋាកនឹងត្រូវបានពង្រឹងបន្ថែមដោយការបង្កើតនូវប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារតាមរយៈការអភិវឌ្ឍគោលការណ៍ណែនាំថ្នាក់ជាតិនេះ ដែលសង្ឃឹមថានឹងអាចបញ្ចប់ទាំងស្រុងនៅចុងឆ្នាំ២០២២។**

**អត្ថបទ៖ អ៊ឹង សុដាវី ផ្នែកសុខាភិបាល ការិយាល័យចៃកាប្រចាំប្រទេសកម្ពុជា និង ក្រុមការងារគម្រោង #stringsproject**

**JICA Project for Strengthening In-Service Training System in Cambodia (The Strings) conducted the first workshop at Kampot province for 3 days from 24th to 26th August with the purpose of developing the national guideline of In-service training for nurses in Cambodia. The project holds a series of workshops in August, September and October this year.**

**Participants from the technical working group and the steering committee, which consist of members from Human Resource Development Department (HRDD), Hospital Service Department (HSD) of MoH, National Hospitals (Calmette, Khmer-Soviet Friendship, and National Pediatric), Cambodian Council of Nurses (CCN) and Cambodia Association of Nurses (CAN), enthusiastically and actively discussed the outline of the guideline during the workshop.**

**We expect to improve competency of nurses by establishing in-service training system through the development of guideline, which is expected to finalize within this year.**

**Creditor: Oeng Sodavy, Health Sector, JICA Cambodia Office, and Project team #StringsProject**











